**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
*Kingdom of Wonder*
*feel the warmth*

**ក្រសួងទេសចរណ៍**

លេខ១៦៧/ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០១៧

# ប្រកាស

## ស្ដីពី

## ការគ្រប់គ្រងអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១_**

ប្រកាសនេះមានគោលបំណងកំណត់អំពីវិធានគ្រប់គ្រង អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េសម្រាប់បម្រើទីផ្សារទេសចរណ៍កូរ៉េ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ ២_**

ប្រកាសនេះមានគោលដៅដូចតទៅ ៖

- ដោះស្រាយជាបណ្ដោះអាសន្ននូវបញ្ហាមគ្គុទ្ទេសក៍ទេសចរណ៍ដែលពុំចេះភាសាកូរ៉េ
- ទប់ស្កាត់ការខុសឆ្គងក្នុងការប្រើប្រាស់អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ

**ប្រការ ៣_**

បច្ចេកសព្ទដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចតទៅៈ

អ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលជាជនបរទេស ដែលធ្វើជាអ្នកបកប្រែបន្តផ្ទាល់មាត់នូវអ្វីដែលមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជា កំពុងនិយាយទៅជាភាសាមួយផ្សេងទៀតជូនភ្ញៀវទេសចរ។

មគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលធ្វើជាអ្នកទទួលជូនថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា។

## ជំពូកទី២

## សមត្ថកិច្ចក្នុងការផ្តល់បណ្ណអនុញ្ញាតឱ្យ អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ

**ប្រការ ៤_**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងការផ្តល់បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។

**ប្រការ ៥_**

ការផ្តល់ ឬការបន្តបណ្ណអនុញ្ញាតឱ្យធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ និងការលុបចោលជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍។

**ប្រការ ៦_**

គ្មានបុគ្គលណាម្នាក់អាចធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េបានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេក៍ទេសចរណ៍ភាសាកូរ៉េពីក្រសួងទេសចរណ៍។

## ជំពូកទី៣

## ទិដ្ឋាន និងនីតិវិធីនៃការផ្តល់បណ្ណអនុញ្ញាតឱ្យ អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ

**ប្រការ ៧_**

បុគ្គលដែលមានបំណងធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ត្រូវដាក់ពាក្យស្នើសុំបណ្ណអនុញ្ញាតនៅក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសម្អាង និងព័ត៌មានផ្សេងៗទៀតដូចខាងក្រោម ៖

ក. លិខិតឆ្លងដែន (ថតចម្លងតាមច្បាប់ដើម)។

ខ. វិញ្ញាបណ្ណបត្របញ្ជាក់ការសិក្សាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ (ថតចម្លងតាមច្បាប់ដើម) ។

គ. វិញ្ញាបណ្ណបត្រពិនិត្យសុខភាព និងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមានការឯកភាពពីក្រសួងទេសចរណ៍។

ឃ. លិខិតស្នើសុំរបស់ទីភ្នាក់ងារទេសចរណ៍ ឬសមាគមទេសចរណ៍។

ង. កិច្ចសន្យាគោរពច្បាប់រដ្ឋ។

ច. ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត។

ឆ. រូបថត (៤ x ៦) ថតថ្មីចំនួន ០២សន្លឹក។

**ប្រការ ៨_**

កម្រៃបណ្ណអនុញ្ញាតឱ្យអ្នកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េត្រូវបង់ ៤០០.០០០ (បួនរយពាន់) រៀល។

**ប្រការ ៩_**

មន្ទីរទេសចរណ៍រាជធានី ខេត្តដែលបានទទួលពាក្យស្នើសុំបណ្ណអនុញ្ញាតត្រូវពិនិត្យលើពាក្យស្នើសុំហើយបញ្ជូនសំណុំបែបបទមកក្រសួងទេសចរណ៍ ដោយមានការបញ្ជាក់ឯកភាពពីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការតាមរយៈក្រុមអាជ្ញាបណ្ណទេសចរណ៍របស់ក្រសួងទេសចរណ៍។ នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវទទួលពិនិត្យវិនិច្ឆ័យលើពាក្យស្នើសុំនេះតាមនីតិវិធីដើម្បីចេញបណ្ណអនុញ្ញាតក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីមិនឯកភាពផ្តល់ឱ្យក្រសួងទេសចរណ៍នឹងបញ្ជាក់ពីមូលហេតុច្បាស់លាស់ជូនទៅអ្នកស្នើសុំ។

**ប្រការ ១០_**

នៅពេលអ្នកស្នើសុំបណ្ណអនុញ្ញាតបានបំពេញបែបបទត្រឹមត្រូវឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងចេញបណ្ណអនុញ្ញាតជូនទៅអ្នកស្នើសុំសម្រាប់ធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។

**ប្រការ ១១_**

បណ្ណអនុញ្ញាតឱ្យធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េមានសុពលភាពប្រើប្រាស់សម្រាប់រយៈពេល ០៦(ប្រាំមួយ)ខែ គិតពីថ្ងៃចេញបណ្ណអនុញ្ញាត។ ក្រសួងទេសចរណ៍អាចផ្តល់បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េជាថ្មី តាមតម្រូវការចាំបាច់នៃទីផ្សារទេសចរណ៍កូរ៉េ។

**ប្រការ ១២_**

បណ្ណអនុញ្ញាតឱ្យអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េមិនអាចធ្វើការផ្ទេរ ឬការលក់បានទេ ដោយសារតែបណ្ណអនុញ្ញាតនេះផ្អែកលើគុណវុឌ្ឍិបុគ្គល និងបទពិសោធរបស់ម្ចាស់បណ្ណ។

**ប្រការ ១៣_**

អ្នកកាន់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ត្រូវប្រើប្រាស់បណ្ណអនុញ្ញាតនេះឱ្យបានត្រឹមត្រូវតាមកម្មវត្ថុនៃអាជីពរបស់ខ្លួន ហើយត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ។

ក្នុងករណីមានការខូចខាត ឬបាត់បង់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ម្ចាស់បណ្ណត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុំបណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តទុតិយតាឡើងវិញក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។ អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ត្រូវកាន់តាមខ្លួននូវលិខិតបញ្ជាក់ពីការដឹងឮរបស់សមត្ថកិច្ចមុនពេលទទួលបានបណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តទុតិយតា។

**ប្រការ ១៤_**

ក្រសួងទេសចរណ៍ធ្វើការជ្រើសរើស បណ្តុះបណ្តាលវិក្រឹតការ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េតាមតម្រូវការចាំបាច់។ លក្ខខណ្ឌ និងនីតិវិធីនៃការជ្រើសរើសបណ្តុះបណ្តាល និងវិក្រឹតការត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៤

## ភារកិច្ចរបស់អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ

**ប្រការ ១៥_**

អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េត្រូវមានភារកិច្ចដូចតទៅ៖

ក. អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េត្រូវប្រើប្រាស់មគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េជាអាទិភាព ក្នុងករណីដែលមានមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េគ្រប់គ្រាន់។

ខ. អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ត្រូវស្លៀកពាក់ឯកសណ្ឋានដោយឡែកខុសពីឯកសណ្ឋានមគ្គុទ្ទេសក៍ទេសចរណ៍ពាក់អត្តលេខ និងពាក់បណ្ណអនុញ្ញាតក្នុងពេលបំពេញភារកិច្ច។

គ. អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ត្រូវបំពេញភារកិច្ចជាមួយមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាដោយធ្វើការបកប្រែជូនទេសចរនូវអ្វី ដែលមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាបានអធិប្បាយពន្យល់។

ឃ. ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យបានល្អ។

ង. អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េមិនត្រូវទាមទារកម្រៃ ឬផលប្រយោជន៍ពីអ្នកលក់ ឬពីអ្នកផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗ។

ច. មិនត្រូវសេពគ្រឿងញៀន សារធាតុស្រវឹង និងសារធាតុញៀននៅក្នុងខ្លួន។ ហាមមានអាវុធជាតិផ្ទុះនៅជាប់ខ្លួន។

ឆ. ជៀសវាងការធ្វើសកម្មភាព ដែលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយជាតិលើវិស័យទេសចរណ៍។

ជ. ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្មដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្រប ដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ឈ. ប្តឹង ឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុតក្នុងករណីដឹង ឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើសការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួយដូរ និងការបង្ហាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត។

ញ. ចូលរួមចំណែកនៅក្នុងការថែរក្សាធនធានធម្មជាតិ លម្អបៃតង មិនពុល ឬមិនបំផ្លាញបរិស្ថាន ការពារ និងអភិរក្សមរតកវប្បធម៌ ការពារសម្បត្តិវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរ ក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន។

ដ. ពេលឈប់ធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ សាមីខ្លួនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងប្រគល់បណ្ណអនុញ្ញាតមកក្រសួងទេសចរណ៍យ៉ាងយូរ ០១ (មួយ)ខែ ក្រោយថ្ងៃឈប់ធ្វើជាអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។ ក្រោយការសុំឈប់ និងប្រគល់បណ្ណអនុញ្ញាតមកក្រសួងទេសចរណ៍វិញ អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េនៅតែមានសិទ្ធិស្នើសុំប្រកបអាជីវកម្មឡើងវិញ ស្របតាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍។

ឋ. សហការជាមួយមន្ត្រីជំនាញនិងមន្ត្រីអធិការកិច្ចទេសចរណ៍ក្នុងការផ្តល់ព័ត៌មាន និងការធ្វើអធិការកិច្ច។

ឌ. គាំទ្រ និងចូលរួមយុទ្ធនាការឃោសនាផ្សព្វផ្សាយ **កម្ពុជា : ព្រះរាជាណាចក្រអច្ឆរិយៈ** និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋាន សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" និងជំរុញចលនាទេសចរក្នុងស្រុកឱ្យមានកំណើនខ្ពស់។

ឍ. ចូលរួមក្នុងយុទ្ធនាការទេសចរណ៍បៃតង "ទេសចរម្នាក់ដាំដើមឈើ១ដើម" ដើម្បីគាំទ្រការកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកំដៅលើផែនដី។

ណ. ចូលរួមវគ្គបណ្តុះបណ្តាល និងវិក្រឹតការដែលរៀបចំដោយក្រសួងទេសចរណ៍។

## ជំពូកទី៥

## ទណ្ឌកម្ម

**ប្រការ ១៦ _**

អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ ដែលប្រើប្រាស់បណ្ណអនុញ្ញាតហួសសុពលភាពរយៈពេល ១០(ដប់)ថ្ងៃ ចាត់ទុកថាធ្វើអាជីវកម្មដោយគ្មានបណ្ណអនុញ្ញាត នឹងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល។

ការពិន័យអន្តរការណ៍នេះ មិនទាន់គិតកម្រៃអាជ្ញាបណ្ណដែលត្រូវបង់។ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ណ ដើម្បីចូលខ្លួនបង់ប្រាក់នៃការពិន័យអន្តរការណ៍ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ។

ក្នុងករណីផុតកាលកំណត់នៃសេចក្តីជូនដំណឹង ប្រសិនបើម្ចាស់បណ្ណមិនព្រមទទួលការពិន័យអន្តរការណ៍នេះទេ នឹងត្រូវទទួលការលុបចោលបណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។

ការពិន័យអន្តរការណ៍មិនធ្វើឱ្យម្ចាស់បណ្ណដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី ឬការទទួលត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

**ប្រការ ១៧_**

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍ដោយគ្មានបណ្ណអនុញ្ញាត ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល និងអតិបរមាមិនលើសពី ៤.០០០.០០០ (បួនលាន) រៀល។ ចំពោះការបង់ប្រាក់ពិន័យអន្តរការណ៍នេះ ក្រសួងទេសចរណ៍នឹងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ណក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីដែលម្ចាស់បណ្ណមិនមកបង់ប្រាក់ពិន័យអន្តរការណ៍តាមសេចក្តីជូនដំណឹងទេ ក្រសួងទេសចរណ៍នឹងសាងសំណុំរឿងបញ្ជូនទៅតុលាការ។

**ប្រការ ១៨_**

បុគ្គលដែលផ្តល់ព័ត៌មានមិនពិតទាក់ទងនឹងការដាក់ពាក្យស្នើសុំបណ្ណអនុញ្ញាត ឬខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ ឬលក្ខខណ្ឌណាមួយនៃបណ្ណអនុញ្ញាត ក្រសួងទេសចរណ៍អាចលុបចោលបណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។

ក្នុងករណីដែលបណ្ណអនុញ្ញាតត្រូវបានលុបចោល ក្រសួងទេសចរណ៍នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បណ្ណក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃជាមុន ដោយបញ្ជាក់ហេតុផលច្បាស់លាស់។ សេចក្តីជូនដំណឹងនេះត្រូវបិទនៅខាងមុខក្រុមហ៊ុនទេសចរណ៍ និងសមាគមឧស្សាហកម្មទេសចរណ៍ក្នុងស្រុកទុកជាព័ត៌មាន។

**ប្រការ ១៩ _**

ក្នុងករណី ម្ចាស់បណ្ណអនុញ្ញាតអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េប្រព្រឹត្តរំលោភលើកាតព្វកិច្ច ដូចមានចែងក្នុងប្រការ ១៥ ជំពូកទី៤ នៃប្រកាសនេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ១.០០០.០០០ (មួយលាន) រៀល និងអតិបរមាមិនលើសពី ១០.០០០.០០០ (ដប់លាន) រៀល។

ការពិន័យអន្តរការណ៍នេះមិនធ្វើឲ្យម្ចាស់បណ្ណអនុញ្ញាតរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ២០_**

ត្រូវបានចាត់ចូលជានិរាករណ៍នូវប្រកាសលេខ ០៩២ ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងអ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ។

**ប្រការ ២១_**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២២_**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ វិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ និងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តតាមស្មារតីប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

**ថោង ខុន**

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត

*"ដើម្បីជូនជ្រាប"*

- សមាគមឧស្សាហកម្មទេសចរណ៍
- អ្នកបកប្រែភាសាកូរ៉េបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ភាសាកូរ៉េ

*"ដើម្បីអនុវត្ត"*

- ដូចប្រការ ២២ *"ដើម្បីមុខការ"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ